BMI0045

# សម្ភាសន៍ជាមួយឈ្មោះ តឹង ប៉ាច ភេទប្រុស

មុខងារសម័យខ្មែរក្រហមៈ ទាហាន

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅភូមិកញ្ឆិល ឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០០:៤១:៤៧

សរុបទំព័រៈ២០

ដានីៈ លោកពូឈ្មោះអីដែរ?

ប៉ាចៈ ខ្ញុំឈ្មោះតឹង ប៉ាច!

ដានីៈ លោកពូមានស្រុកកំណើតនៅណាដែរ?

ប៉ាចៈ នៅភូមិកញ្ឆិល!

ដានីៈ ឃុំអី?

ប៉ាចៈ ឃុំកំពង់រាប ស្រុកព្រៃកប្បាស!

ដានីៈ ស្រុកព្រៃកប្បាស ខេត្តតាកែវ?

ប៉ាចៈ បាទ!

ដានីៈ កាលហ្នឹងពូចេញពីផ្ទះតាំងពីអង្កាល់?

ប៉ាចៈ ចេញតាំងពីឆ្នាំ១៩៧៣!

ដានីៈ ចេញតាំងពីឆ្នាំ៧៣?

ប៉ាចៈ កាលជំនាន់សង្គ្រាមលន់ នល់ហ្នឹង!

ដានីៈ កាលសង្គ្រាមលន់ នល់ កាលជំនាន់សម្តេចអំពាវនាវយើងហ្នឹង?

ប៉ាចៈ បាទ! រដ្ឋប្រហារឆ្នាំ៧៣ហ្នឹង កាលជំនាន់៧០ខ្ញុំនៅរៀនដល់រដ្ឋប្រហារបានឈប់ៗ

ដានីៈ កាលហ្នឹងពូរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ប៉ាចៈ ថ្នាក់ទី៧! ទី៧ពីដើម គេអត់រាប់ដូចយើងឥលូវថ្នាក់ទី១ធំទេណា៎! ដូចថាថ្នាក់ទី១២ ថ្នាក់ទី១១ហើយថ្នាក់ទី៧!

ដានីៈ បាទ!

ប៉ាចៈ គិតទៅរៀនបានមួយឆ្នាំពីរឆ្នាំហ្នឹង!

ដានីៈ ពូមានបងប្អូនប៉ុន្មាននាក់?

ប៉ាចៈ ខ្ញុំមានបងប្អូនច្រើនណាស់ដល់ទៅ៩នាក់នុះ!

ដានីៈ ៩នាក់?

ប៉ាចៈ បាទ!

ដានីៈ ៩នាក់ហ្នឹងបានរៀនសូត្រទាំងអស់គ្នាដែរ?

ប៉ាចៈ កាលពីឆ្នាំ៧៣ខ្ញុំចេញម៉ោហ្នឹងបងប្អូនខ្ញុំនៅតូចៗវាអត់ទាន់បានរៀនទេ!

ដានីៈ ៩នាក់ហ្នឹងពូបងគេ?

ប៉ាចៈ ខ្ញុំទី២ បន្ទាប់បង!

ដានីៈ ទីពីរ?

ប៉ាចៈ បាទ!

ដានីៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ប៉ាចៈ ប្រុស៥ស្រី៤!

ដានីៈ ប្រុស៥ស្រី៤?

ប៉ាចៈ បាទ!

ដានីៈ កាលហ្នឹងពូចេញទៅតែម្នាក់ឯងទេ?

ប៉ាចៈ បងនៅៗបានបួសបានអីនៅស្រុក!

ដានីៈ អ៎! ពូមានបានបួសដែរទេ?

ប៉ាចៈ អត់ទេ!

ដានីៈ ពូអាយុប៉ុន្មានហើយ?

ប៉ាចៈ ខ្ញុំគិតទៅវាឆ្នាំមមែវាចូល៥៥,៥៦ហើយ!

ដានីៈ ចូល៥៦ហើយ?

ប៉ាចៈ បាទ!

ដានីៈ កាលពូនៅផ្ទះគ្រួសារពូធ្វើអីគេ?

ប៉ាចៈ នៅស្រុកមែន?

ដានីៈ បាទ!

ប៉ាចៈ ធ្វើស្រែចំការបន្តិចបន្តួចហ្នឹង!

ដានីៈ ធ្វើស្រែធ្វើចំការ?

ប៉ាចៈ ព្រោះកាលហ្នឹងនៅក្នុងស្រុកខ្ញុំវាសំបូទឹកណាស់ ខែហ្នឹងអញ្ចឹងវាមានតែស្រែហើយនឹងទឹកទេ ហើយខែត្រីយើងដាក់មង ដាក់សំណាញ់ ដាក់អួនដាក់អីអញ្ចឹងព្រោះទឹកវាលិច ម៉ាដូនៅខាងនេះទឹកលិចអស់ហើយពីដើមអត់មានអ្នកណាធ្វើស្រែប្រាំងដូចឥលូវទេ ធ្វើតែស្រែយើងអាស្រែព្រោះហ្នឹង ហើយដូចឥលូវគេអត់សូវធ្វើស្រែព្រោះគេធ្វើតែស្រែប្រាំងនៅក្នុងស្រុកហ្នឹងស្រួលដែរ!

ដានីៈ ចុះឪពុកម្តាយពូសព្វថ្ងៃគាត់នៅទេ?

ប៉ាចៈ គាត់ស្លាប់អស់ហើយ!

ដានីៈ គាត់ស្លាប់តាំងពីអង្កាល់?

ប៉ាចៈ ឪពុកម្តាយខ្ញុំគិតទៅស្លាប់តាំងពីឆ្នាំ៧៦!

ដានីៈ គាត់ស្លាប់ដោយសារមូលហេតុអី?

ប៉ាចៈ និយាយទៅវាពិបាកប្រវត្តកាលហ្នឹងវាពិបាកនិយាយ អញ្ចឹងកាលហ្នឹងខ្ញុំធ្វើទាហានធ្វើទ័ពដល់ហើយគេថាយកឪពុកម្តាយទៅទុកកន្លែងសំបូរហូបអី ហើយមិនយកទៅទុកកន្លែងសំបូហូបអីវាយកទៅទុកកន្លែងធ្វើបាប ស្លាប់ហ្នឹងខ្ញុំទាន់គាត់ដែរខ្ញុំទៅកាលយើងចប់សង្រ្គាមជិនាន់លន់ នល់ហើយយើងចប់សង្រ្គាមខ្ញុំទៅនៅលើកទំនប់ ដល់ទៅលើកទំនប់ខ្ញុំទៅៗជួបម៉ែខ្ញុំនៅកន្លែងដែលវាយកទៅទុកដាក់នោះ គាត់ឈឺហើយប្អូនពៅខ្ញុំមួយ ហើយខ្ញុំគេបេះតែឲ្យទៅដឹកត្រីដែរបើកកាណូតនៅក្នុងទឹក ហើយខ្ញុំបើកទៅយកត្រីនៅអង្គបុរីយើងនេះដល់ចូលទៅជួបគាត់បងប្អូនគេនៅនោះ ដល់ចូលទៅជួបគាត់ក៏យកត្រីទៅឲ្យគាត់ ហើយខ្ញុំទៅពួកហ្នឹងវារត់អស់ចុះខ្ញុំនៅទ័ពដែរកាលហ្នឹង ។

ដានីៈ គេយកគាត់ទៅធ្វើបាប?

ប៉ាចៈ វាយកទៅបង្អត់បាយបង្អត់ទឹកហ្នុង!

ដានីៈ ម៉េចបានគេធ្វើអញ្ចឹង?

ប៉ាចៈ អញ្ចឹងបានថាខ្ញុំវាមិនដឹងមូលហេតុអីដែរ!

ដានីៈ គាត់ឈ្មោះអី?

ប៉ាចៈ ម្តាយខ្ញុំឈ្មោះទូច! អាហ្នឹងបើតាមទិសដៅសំខាន់ខ្ញុំមិនសូវដឹងទេព្រោះខ្ញុំនៅទាហាន ដល់ពេលគេនិយាយគេថាយកឪពុកម្តាយគ្រួសារយោធាដែលមានកូនម៉ោទ័ពហ្នឹងយកទៅ

ដើម្បីឲ្យមានហូបចុកអីគ្រប់គ្រាន់តែដុយទៅវិញវាធ្វើអញ្ចឹងវាយកទៅធ្វើបាបវិញ វាធ្វើបាបបង្អត់បាយបង្អត់ទឹកហ្នឹង អាហ្នឹងដូចតែយកទៅសម្លាប់អញ្ចឹង ជំនាន់ហ្នឹងដូចសម្លាប់អញ្ចឹងជំនាន់បីឆ្នាំហ្នឹង!

ដានី៖ អញ្ចឹងគាត់ស្លាប់ពេលហ្នឹង?

ប៉ាច៖ បាទគាត់ស្លាប់តាំងពីឆ្នាំ៧៦,៧៧ហ្នឹង៦ង!

ដានី៖ ចុះឪពុកពូ?

ប៉ាច៖ ឪពុកខ្ញុំទើបតែស្លាប់បានប៉ុន្មានដែរហ្នឹង ឪពុកខ្ញុំស្លាប់បានបួនប្រាំឆ្នាំហើយ!

ដានី៖ គាត់ឈ្មោះអីដែរ?

ប៉ាច៖ គាត់ឈ្មោះ សៀម!

ដានី៖ គាត់ឈឺមែន?

ប៉ាច៖ គាត់ឈឺ!

ដានី៖ អញ្ចឹងតាំងពី៧៣ម៉ោពូមកធ្វើកងទ័ពហ្មង?

ប៉ាច៖ បាទធ្វើទ័ពរហូត!

ដានី៖ ធ្វើទ័ពនៅណាទៅ?

ប៉ាច៖ កាលមុនខ្ញុំនៅតំបន់យើងខេត្តតាកែវយើងហ្នឹង ដល់ពេលឆ្នាំ៧៦នេះបានគេរើសទ័ពទាហានម៉ោខាងពាយ័ព្យវិញ យកមកនៅភ្នំពេញមកនៅខាងជើងថ្នូរពួកហ្នឹង ហើយធ្លាប់នៅដល់អញ្ចឹងចេះតែនៅទ័ពទាហានហ្នឹងរហូតម៉ោ!

ដានី៖ ហ្នឹងសម័យបីឆ្នាំ?

ប៉ាច៖ បាទសម័យបីឆ្នាំហ្នឹង!

ដានី៖ សម័យបីឆ្នាំពូនៅភ្នំពេញឬក៏នៅខាង....?

ប៉ាច៖ នៅថ្នូរពួក ចេញពីភ្នំពេញម៉ោ!

ដានី៖ ថ្នូរពួកខាង...?

ប៉ាច៖ ខាងជើងផ្លូវជាតិលេខ៥យើងហ្នឹង! ខាងប៉ោយប៉ែតយើងហ្នឹង!

ដានី៖ ផ្លូវប៉ោយប៉ែត?

ប៉ាច៖ បាទទៅបន្ទាយឆ្មារបន្ទាយអីហ្នឹង! ដល់ហើយចេះតែវៃគ្នាដល់អញ្ចឹងសង្គ្រាមវៃម៉ោចេះតែរត់ទៅនេះទៅនោះ ហើយក៏បានធ្លាក់មកនៅខាងត្បូងថ្នល់នេះវិញៗ

ដានី៖ ចុះដល់ពេល៧៩ពេលដែលយួនចូល?

ប៉ាចៈ អាហ្នឹងរត់ម៉ោខាងនេះវិញ! អាហ្នឹងយួនដេញម៉ោរត់ម៉ោខាងនេះទៅជួរយើងបារាំងជួរតាមព្រំដែនហ្នឹង កាល៧៩ភាគច្រើនអត់បាននៅដីខ្មែរទេភាគច្រើននៅដីថៃទេ កាលហ្នឹងកម្លាំងខ្មែរក្រហមវាបាក់ដូចថាចាញ់គេណា៎ ដល់អញ្ចឹងយើងចេះតែរត់ទៅផ្អើសស្គ្រាមឈប់ចុះឡើងបានៗចូលម៉ោក្នុងស្រុកវិញ ។

ដានីៈ កាល៧៩ហ្នឹងរត់មកនៅដីថៃវិញ?

ប៉ាចៈ បាទ! រត់ម៉ោខ្លះនៅដីថៃខ្លះនៅដីខ្មែរអញ្ចឹងទៅ ថៃវាខបត្ថម្ភ កាកបទក្រហមគេជួយជាស្បៀងជាអីម៉ោ!

ដានីៈ កាលហ្នឹងពូនៅកងពលណា?

ប៉ាចៈ នៅកងពល៥១!

ដានីៈ កងពល៥១?

ប៉ាចៈ បាទ! ម៉ោនេះនៅកងពល៥១!

ដានីៈ មិនមែនកងពល៤៥០ទេ?

ប៉ាចៈ ៤៥០ហ្នឹងមុន កាលមុន៤៥០ដល់ម៉ោសព្វថ្ងៃនេះកងពល៥១! ប៉ុន្តែសព្វថ្ងៃនេះខ្ញុំសម្រាកហើយព្រោះទាហានគេឲ្យកាត់ ទាហានកាត់គេណា!

ដានីៈ កាល៧៩គេហៅកងពលអីដែរ?

ប៉ាចៈ អាហ្នឹងកងពល៤៥០! កាលហ្នឹងវាពិបាកព្រោះវាច្រើនផ្នែកទៀតណា៎ ក្រោយហើយដឹងតែមកនៅនេះ៤៥០ហើយបានទៅកងពលយើង៥១សព្វថ្ងៃនេះ ។

ដានីៈ ដំបូងយើងមកនៅខាងម៉ាឡៃហ្នឹងហ្នងឬក៏នៅណា? ពេលដែលកម្លាំងបាក់ហើយរត់ទៅនៅដីថៃ?

ប៉ាចៈ អត់ទៀងដែរជួនកាលទៅនៅបន្ទាយបឹងបេងទៅ ជួនកាលមកនៅនេះម៉ោតែនៅក្នុងស្រុកម៉ាឡៃដែរទេណា៎ ហើយជួនកាលទៅនៅខាងស្វាងាប់អញ្ចឹងទៅតែសុទ្ធតែក្នុងស្រុកម៉ាឡៃដូចគ្នាដែរ គេចហ្នឹងវាគេចច្រើនកន្លែង ពេលគេជម្លៀសឲ្យទៅនៅខាងនោះក៏ទៅតាមគេទៅដល់ខាងនោះសភាពការណ៍អត់ស្រួលគេឲ្យម៉ោខាងនេះក៏ម៉ោខាងនេះវិញម៉ោ!

ដានីៈ សុទ្ធតែកងទ័ពឬក៏មានប្រជាជនដែរកាល៧៩?

ប៉ាចៈ កាលមួយជំនាន់ហ្នឹងអត់មានប្រជាជនទេគឺមានសុទ្ធតែទ័ព អាហ្នឹងអត់ទាន់មានគ្រួសារមានអី ទេ!

ដានីៈ កាលហ្នឹងមានតែសុទ្ធតែប្រុសៗ?

ប៉ាចៈ កាលហ្នឹងស្រីក៏មានដែរ តែអត់ទាន់សូវមានប្រពន្ធមានកូនទេ!

ដានី៖ ស្រីៗហ្នឹងធ្វើទ័ពដែរ?

ប៉ាច៖ ស្រីខាងដឹកជញ្ជូនដឹកអីចឹងទៅ!

ដានី៖ អ៎ខាងដឹកជញ្ជូន?

ប៉ាច៖ បាទ! កាលជំនាន់ហ្នឹងជម្លៀសម៉ោចេះតែម៉ោណា៎ ម៉ោចឹងទៅស្រីៗខាងដឹកជញ្ជូនប្រុសធ្វើទ័ពធ្វើទាហានអញ្ចឹងទៅ!

ដានី៖ ស្រីៗដឹកជញ្ជូនឲ្យប្រុសៗអ្នកគ្រប់គ្រង?

ប៉ាច៖ បាទ!

ដានី៖ ស្រីៗនៅខាងណាប្រុសៗនៅខាងណាដែរ?

ប៉ាច៖ នៅតែខាងហ្នឹងដូចគ្នាអញ្ចឹង!

ដានី៖ ខាងដូចថានៅយើងនៅជាមួយគ្នាឬក៏?

ប៉ាច៖ អត់ទេគេនៅតាមអង្គភាពគេទេ ដូចថានៅខាងនារីអញ្ចឹងគេនៅមួយដុំអញ្ចឹងទៅ ហើយប្រុសៗខាងយុទ្ធជនអញ្ចឹងគេនៅមួយដុំអញ្ចឹងទៅឬក៏នៅតាមព្រំដែនតាមអង្គភាពគេហ្នឹងក្រុមនារីគេខបត្តម្ភទាហានប៉ុន្មាន កងទ័ពយើងប៉ុន្មានដែលត្រូវដឹកជញ្ជូនគេនៅជិតៗគ្នាហ្នឹងគេនោះគេនៅអញ្ចឹងដែរម៉ាក្រុមៗ ម៉ាកងចឹងទៅ ។

ដានី៖ ចុះកាលហ្នឹងពេលដែលយើងនៅម្តុំហ្នឹងពេលដែលយើងវៃជាមួយពួកខាងកងទ័ពខាងក្នុងម៉ោយ៉ាងម៉េចដែរ វៃញឹកញាប់ដែរឬក៏មិនសូវទេ?

ប៉ាច៖ ញឹកញាប់ដែរគ្រាន់តែសង្គ្រាមឆ្នុះតិចៗ! វាគ្រាន់តែឆ្នក់ដូចថាទាហានវានៅអញ្ចឹងអាពួកម៉ាក្រុមវាទៅបាញ់ទូងៗយើងដកទៅ ព្រោះអាហ្នឹងយើងទប់ទល់នឹងកម្លាំងវាអត់បានទេព្រោះកម្លាំងយើងតិចយើងធ្វើសង្គ្រាមឈ្លប បើចង់ឲ្យគេវៃគេវៃតាមមុខសញ្ញាគេទៅកម្លាំងតិចមែនតែគេរាយតាមព្រំដែន ដូចថាកន្លះគីឡូអញ្ចឹងមួយក្រុមទៅ មួយរយម៉ែត្រមួយពួកទៅដាក់តាមព្រំដែនទៅ តែអត់មានវៃធំទេគ្រាន់តែវៃឆ្នក់ទេ!

ដានី៖ កងកម្លាំងមានយួនដែរ?

ប៉ាច៖ កងកម្លាំងក្នុងហ្នឹងច្រើនមានទាំងយួននឹងទាហានខ្មែរ!

ដានី៖ រដ្ឋកម្ពុជា?

ប៉ាច៖ ហ្នឹងអើយរដ្ឋកម្ពុជាយើងហ្នឹង!

ដានី៖ អញ្ចឹងកាលហ្នឹងយើងធ្វើដុះធ្វើអីដែរទេតាំងពីដំបូង?

ប៉ាចៈ អត់ទេយើងអត់មានធ្វើផ្ទះធ្វើអីទេ គ្រាន់តែប្រក់កៅស៊ូធ្វើជារោងតូចៗសម្រាប់នៅមួយ រយៈមិនមែនយើងបោះទីតាំងនៅកន្លែងហ្នឹងបានទេអត់ទេ ដូចថាពេលណាខាងលើគេត្រូវការថាអន្តរាយហ្នឹងដូរទៅខាងនោះយើងទៅទៀតទៅ យើងសារអន្ទើងសារអីទៅតាមគេទៅគ្មានផ្ទះគ្មានសំបែងអីស្រួលបួលទេ ចុះកាលហ្នឹងសុទ្ធតែព្រៃទាំងអស់អត់មានវាលទេសុទ្ធតែព្រៃទីនោះ!

ដានីៈ សុទ្ធតែព្រៃ?

ប៉ាចៈ បាទ!

ដានីៈ គេហៅអីទៅពូ? គេហៅម៉ាឡៃមែនពូ?

ប៉ាចៈ អត់ទេមុនដំបូងគេហៅភូមិដូងៗ!

ដានីៈ ភូមិដូង?

ប៉ាចៈ បាទម៉ាឡៃបែបទើបតែដាក់ដែរទេមើលទៅ ម៉ាឡៃដោយសារភ្នំទេបានគេហៅម៉ាឡៃៗហ្នឹងប៉ុន្តែបើភ្នំម៉ាឡៃមែនទែននៅខាងកើតមិនដឹងភ្នំមួយណាទេ?

ដានីៈ ចុះម៉េចបានគេហៅភូមិដូងវាសុទ្ធតែព្រៃមែនដំបូង?

ប៉ាចៈ មិនដឹងយ៉ាងម៉េចប្រហែលវាជាប់រយៈភូមិដូងថៃហ្នឹងដែលគេហៅខ្នងស្ពឺៗនោះ ដល់អញ្ចឹងវាពិបាកដែរ ខ្ញុំមិនសូវដឹងប្រវត្តិដែរគ្រាន់ថាយើងម៉ោចេះតែហៅតគ្នាអញ្ចឹងទៅ!

ដានីៈ ហៅតាមគ្នាអញ្ចឹងទៅ?

ប៉ាចៈ បាទ!

ដានីៈ កាលហ្នឹងពេលយើងធ្វើកងទ័ពវៃហ្នឹងដូចការហូបចុកអីយ៉ាងម៉េចដែរ ហូបរបស់របរអីបានម៉ោពីណា?

ប៉ាចៈ ខាងកាកបាទជួយ!

ដានីៈ ខាងកាកបាទ?

ប៉ាចៈ ខាងកាកបាទក្រហម! គេជួយគាំទ្រខាងកម្លាំងតស៊ូខ្មែរក្រហមយើងហ្នឹង មានតាំងពីប្រហុក មានតាំងពីអំបិល មានតាំងពីស្ករមួយចប់ គាំងពីសម្លៀកបំពាក់យើងទាហានគេបើកឲ្យគ្រប់គ្រាន់ម៉ាយើងប្រើប្រាស់កៅស៊ូភ្លៀងខោអាវអញ្ចឹងទៅ!

ដានីៈ បាទ!

ប៉ាចៈ ហើយមីងអញ្ចឹងគេបើកសារ៉ុងបើកអីឲ្យអញ្ចឹង ព្រោះយើងអត់ទាន់មានប្រើលុយណា៎ មិនទាន់ចាយលុយប៉ុន្មានទេ! ៧៩,៨០ អីហ្នឹងយើងអត់ទាន់ចាយលុយទេ ខ្លះមានមាសបន្តិច

បន្តួចទៅដូរយកអង្ករយកអីអញ្ចឹងទៅ បើមែនទែនទៅតាំងពីឆ្នាំ៨២យើងសំបូរហូបព្រោះបានកាកបទក្រហមគេជួយ ពីមុនក៏អត់ទាន់មានដែរព្រោះយើងនៅជាមួយអ្នកដឹកនាំគាត់ជួយគិតក់ៗទៅវាបានអង្ករហូបអីហូប ដឹកដំឡូងដឹកអីហូបអញ្ចឹងទៅ ដល់ឆ្នាំ៨១,៨២បានកាកបទគេជួយបានហូបគ្រប់គ្រាន់វិញ ។

ដានី: ដល់ពេលអញ្ចឹងនៅហ្នឹងរហូតដល់ សមាហរណកម្មបុក៏មានការផ្លាស់ប្តូរអី?

ប៉ាច: ផ្លាស់! មានការផ្លាស់ប្តូរដែរ! ផ្លាស់ទៅនៅនេះតិចនោះតិចអញ្ចឹងទៅ នៅស្រុកហ្នឹងទេអត់ទៅឆ្ងាយទេ មុននៅស្វាងរាប់ដល់គេដូរទៅនៅនោះប្រចាំការនៅនោះក៏ទៅៗ!

ដានី: ចុះកាលជំនាន់ឆ្នាំណាដែលយួនចូលម៉ោ?

ប៉ាច: អាហ្នឹង៧៩!

ដានី: ៧៩ហ្នឹងគេចូលម៉ោដល់ហ្នុង?

ប៉ាច: ហ្នឹងអើយគេចូលម៉ោដល់តាមព្រំដែន!

ដានី: ហើយយើងទៅនៅណា?

ប៉ាច: យើងនៅតាមព្រំដែន! នៅព្រំដែនតែនៅខាងដីថៃ! នៅម្ខាងអូរនេះ!

ដានី: កាលយើងទៅនៅខាង៨៥អី?

ប៉ាច: បាទ! អាហ្នឹងដល់ពេលនេះអញ្ចឹងគេយកខាងមីងៗគ្រួសារទាហានហ្នឹងយកទៅនៅ៨៥ ហើយប្តីគ្រួសារហ្នឹងក៏ទៅនៅហ្នឹងដែរ តែដល់ហើយគេប្រមូលយកមកឲ្យនៅតាមព្រំដែនបុក៏ឲ្យចូលទៅក្នុងវិញ ទាហាននៅហ្នឹងក៏មានកម្លាំងជាងទាហាននៅក្នុងដែរ ធ្វើការនៅក្នុង!

ដានី: ធ្វើការនៅខាងក្នុង?

ប៉ាច: បាទ!

ដានី: កាលហ្នឹងយួនចូលម៉ោនៅហ្នឹងពេញ?

ប៉ាច: បាទ! នៅហ្នឹងមានរដ្ឋកម្ពុជាហើយយួនអីមកនៅតាមព្រំដែន យើងចេះតែចេញចូលហើយវាដាក់មីនតាមព្រំដែនហ្នឹងរហូត មានរបងលួសអីយើងចេះតែរាវ ដើរកាត់អីម៉ាដូយើងដើរកាត់តាមដងស្ទឹងអញ្ចឹងណាពួកទាហាន!

ដានី: ហើយយើងរៃដែរ?

ប៉ាច: បាទរៃ ហើយទៅនោះមានប្រជាជនគាត់ជួយជាអង្ករជាអីម៉ោធ្វើជានយោបាយអញ្ចឹងណា៎ខ្លះទម្លាក់ដាក់តាមបំពង់យកមកឲ្យយើងហូបទៅ ដល់ពេលប្រជាជនអត់ជួយយើងមានអី ហូបប្រជាជនគាត់ចេះតែជួយយើងធ្វើនយោបាយហ្នឹងវាល្អដែរ ដល់អញ្ចឹងកម្លាំងវាចេះ

តែមានកម្លាំងឡើង ដល់អញ្ចឹងកម្លាំងកាន់តែធំអាចរើអាចអីអញ្ចឹងទៅណា៎ ដល់ទៅបានឆ្នាំ ៨០ប៉ុន្មានទេបានយួនវាដកទៅវិញទៅ ហើយបានយើងសមាហរណកម្មនេះត្រូវគ្នាម្ដង សម្ដេចហ៊ុន សែន គាត់ធ្វើនយោបាយល្អទៅត្រូវគ្នាទៅបាននៅហ្នឹងជាប់រហូតបានកើតជា ផ្ទះធំៗអញ្ចឹងទៅ!

ដានី: ឆ្នាំណាដែលយួននឹងរដ្ឋកម្ពុជាដកចេញទៅវិញអស់?

ប៉ាច: អាហ្នឹងដូចជាឆ្នាំ៩៥!

ដានី: ៩៦យើងសមាហរណកម្ម?

ប៉ាច: បាទ! អាច៩៤បុ៩៥វាដកចេញបណ្ដើរៗ ហើយបានកម្លាំងយើងមកនៅតាមព្រំដែន ដល់ពេលសមាហរណកម្មហ្នឹងដកកម្លាំងពីថៃពីអីម៉ោមកនៅហ្នឹងអស់!

ដានី: ចុះពេលដែលគេដកចេញអស់យើងចូលមកនៅមានផលលំបាកអីដែរអត់ទេ?

ប៉ាច: ពិបាកដែរពិបាករឿងខុបស័ក្តរឿងមីន!

ដានី: រឿងមីន?

ប៉ាច: ព្រោះមីនវាដាក់ច្រើន មីនយួនណា៎!

ដានី: បាទ! មីនច្រើនអញ្ចឹងយើងធ្វើម៉េចទៅ?

ប៉ាច: យើងចេះរាវចេះអីខ្លះទៅ គ្រោះថ្នាក់ច្រើនណាស់រឿងមីន ចុះបើតាមហ្នឹងវាដាក់មីនពេញ ហ្នឹងទាំងអស់ ដាច់ជើងដាច់អីច្រើនតែមកនៅតាមព្រំដែនហ្នឹង អាខ្លះគ្នាអត់ចុះយើងកាល ហ្នឹងមានទាន់សំបូរណាប៉ុន្មាន ដល់អញ្ចឹងគ្នារាវទៅវាប៉ះទៅដាច់ជើងដាច់អីអញ្ចឹងទៅ!

ដានី: បាទ!

ប៉ាច: មានច្រើន! ទើបតែម៉ោពួកស៊ីម៉ាក់យើងចាប់ផ្ដើមមកដោះនេះបានប្រជាជនយើងបាននៅ តាមហ្នឹងធ្វើចំការធ្វើស្រែតាមមាត់អូរហ្នឹង កាលមុនស្ងួតតែមីនហ្នង!

ដានី: ចុះពូរៀបការជាមួយមីងឆ្នាំណាដែរ?

ប៉ាច: ឆ្នាំ៨១!

ដានី: ឆ្នាំ៨១?

ប៉ាច: បាទខាងលើគេរៀបការឲ្យ វាមិនមានចាស់ទុំណាធ្វើភ្ញៀវឲ្យទេ គ្រាន់តែខាងលើគេរៀបការ ឲ្យក៏យកគ្នាទៅ ប៉ុន្តែគ្រាន់តែខាងលើគេដឹងពុ្ង ក្នុងអង្គភាពយើងដឹងពុ្ងអត់បានការដូចយើង ឥលូវទេ!

ដានី: ចុះកាលហ្នឹងម៉េចស្គាល់មីង?

ប៉ាចៈ ខ្ញុំមានពូខ្ញុំមួយនៅចក្រីគាត់និយាយឲ្យ ហើយខ្ញុំនៅនេះទេគ្រួសារខ្ញុំអីនៅចក្រី!

ដានីៈ អញ្ចឹងមីងនៅចក្រីទេ?

ប៉ាចៈ បាទហើយខ្ញុំនៅខាងនេះ!

ដានីៈ ចក្រីនៅខាង...?

ប៉ាចៈ ប្រាំងល័ក្ខ! នៅមួយជួរខាងភ្នំប្រាំងល័ក្ខយើងហ្នឹង!

ដានីៈ នៅខាងកាប៊ីនអីហ្នឹង?

ប៉ាចៈ បាទ! ម៉ោខាងដើងវិញ ប៉ុន្តែខ្ញុំនៅខាងនេះ!

ដានីៈ អញ្ចឹងគាត់ទាក់ទងឲ្យទៅ?

ប៉ាចៈ បាទ! ចុះយើងទៅម៉ោគ្នាបានហ្នឹង នៅប្រវែងប៉ុណ្ណឹងយើងទៅម៉ោបានតាមដីថៃទៅជួបបងប្អូនអី!

ដានីៈ បាទ! ចុះមីងគាត់ឈ្មោះអីដែរ?

ប៉ាចៈ វ៉ើត!

ដានីៈ ឈ្មោះ វ៉ើត?

ប៉ាចៈ បាទ!

ដានីៈ ហើយគាត់អ្នកស្រុកកំណើតជាមួយពូដែរ?

ប៉ាចៈ បាទ! នៅជិត

ដានីៈ ភូមិជាមួយប្អូនក៏អត់ទេ?

ប៉ាចៈ អត់ទេ! នៅភូមិឆ្ងាយ នៅប្រហែល៧គីឡូពីគ្នា!

ដានីៈ ឃុំជាមួយគ្នា?

ប៉ាចៈ អត់ទេឃុំដោយឡែក!

ដានីៈ នៅភូមិអីឃុំអីដែរ?

ប៉ាចៈ នៅភូមិល្វាត្នោត ឃុំព្រៃល្វា!

ដានីៈ អ៊ំ!

ប៉ាចៈ ដល់ខ្ញុំនៅភូមិក្រចេះ ឃុំកំពង់រាប ដល់ស្រុកៗជាមួយគ្នា!

ដានីៈ ស្រុកឈ្មោះអី?

ប៉ាចៈ ស្រុកព្រៃកប្បាស!

ដានីៈ ជិតផ្សារជ្រៃដែរឬអត់?

ប៉ាចៈ ខ្ញុំនៅខាងលើនេះវិញ ផ្សារជ្រៃនៅខាងនោះវិញ ជិតគ្នាដែរបើនិយាយទៅវាមិនឆ្ងាយពីផ្សារជ្រៃប៉ុន្មានទេ!

ដានីៈ អញ្ចឹងពេលពូការជាមួយមីងនៅឆ្នាំ៨១ម៉ោហ្នឹងពូនៅជាមួយគ្នារហូតឬក៏អត់ទេ?

ប៉ាចៈ អត់បាននៅជាមួយគ្នារហូតទេ កាលហ្នឹងវានៅសង្គ្រាម បើនៅជាមួយគ្នាទៅមុខក៏ទៅដែរ តែម៉ោវិញក៏ម៉ោៗ ដូចថាម៉ោបួនដប់ថ្ងៃម៉ាម្ដៃថ្ងៃចឹងខាងលើគេជាកម្លាំងត្រូវទៅហៅទៅវិញអញ្ចឹងទៅ កម្លាំងនៅតាមព្រំដែននៅក៏នៅទៅយើងចេញចូលទៅធ្វើការនៅខាងក្នុង!

ដានីៈ ប៉ុន្តែយើងមានផ្ទះសម្រាប់នៅទេ?

ប៉ាចៈ អត់! មានតែខ្ទមតូចៗ ផ្ទះដូចថាយើងធ្វើបីបួនម៉ែត្រសម្រាប់យើងប៉ុន្តែអត់ទាន់មានកូនចៅណាការរួចហើយនៅតែពីរនាក់ អាខ្លះគេចង់តែកៅស៊ូអញ្ចឹងទៅ ហើយកាលហ្នឹងវាទៅនៅ៨៥ហើយដល់ពេលវាជម្លៀសអញ្ចឹងទៅ ដល់ពេល៨៥គេយកខ្ញុំទៅគេធ្វើផ្ទះធ្វើអីឲ្យអញ្ចឹងទៅមេភូមិមេអីម៉ាជំនាន់ហ្នឹងក៏មានដូចគ្នាអញ្ចឹងដែរ!

ដានីៈ បាទ!

ប៉ាចៈ មានមេភូមិមេឃុំគេនៅខាងក្រោយហ្នឹងគេជួយយើងអញ្ចឹងទៅ យើងឈឺស្កាត់អីអត់ឃ្លានអីគេមើល ហើយយើងម៉ោលេងវិញក៏ម៉ោទៅ!

ដានីៈ បាទ!

ប៉ាចៈ សុំច្បាប់ម៉ោបួនដប់ថ្ងៃអញ្ចឹងទៅហើយទៅវិញក៏ទៅៗ អត់មានបាននៅជុំគ្នារហូតដូចសព្វថ្ងៃនេះទេ!

ដានីៈ ចុះពូមានកូនប៉ុន្មាននាក់ដែរ?

ប៉ាចៈ ៤នាក់!

ដានីៈ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ប៉ាចៈ ស្រី២ប្រុស២! ស្រីៗការហើយអស់ហើយ ហើយប្រុសៗនៅរៀនៗ

ដានីៈ សមាហរណកម្មយើងហ្នឹងយ៉ាងម៉េច ដំបូងដូចថាយើងនៅក្នុងកងទ័ពដល់ពេលសមាហរណកម្មហើយនៅផ្ទះនៅអីចឹងគេចែកគ្នាអីឲ្យប៉ុន្មានៗអីចឹង?

ប៉ាចៈ មុនដំបូងគេឲ្យដែរដូចថាយើងទើបតែម៉ោអញ្ចឹងគេឲ្យតែម៉ាប្លង់ៗទេ អាហ្នឹងគេអត់ទាន់ចែកដីកន្លែងនេះទេគេចែកកន្លែងនោះតាមព្រំដែននោះ ដូចថាយើងនៅម៉ាចន្លោះ១២០ម៉ែត្រឬ៣០ម៉ែត្រម្នាក់ កាលហ្នឹងវាមីនមានអ្នកណាហ៊ានទៅទាន់ចង់បានដីណា មានទាន់មានដីធ្វើស្រែធ្វើចំការណាធំដូចសព្វថ្ងៃនេះ ចែកឲ្យតែយើងម៉ានៅធ្វើកូនខ្ទមបួនម៉ែត្រម៉ាគ្រួសារនៅ

អញ្ចឹងទៅ អាខ្លះមានកូនមួយ អាខ្លះអត់ទាន់អញ្ចឹងទៅ អាខ្លះមានកូនពីរអញ្ចឹងទៅ អាហ្នឹងម៉ាជំនាន់ហ្នឹងកូន ដល់ជំនាន់នេះលែងមានហើយ តែអត់ទាន់មានផ្ទះធំមែនទែនទេព្រោះវាទើបតែភ្ញាម១មានតែផ្ទះយើងតូចៗល្មមយើងជ្រកនៅសមរម្យបីបួនម៉ែត្រអីហ្នឹង!

ដានីៈ ដល់ហើយម៉ោបានយើងមកចាប់ដីចាប់អីខ្លួនឯង?

ប៉ាចៈ បាទមកចាប់ដី ចែកហ្នឹងក៏នៅតែមានចែកដែរ ដូចថាដីចំការអញ្ចឹងយើងត្រូវចែកគ្នាមួយអន្តភាពហ្នឹងមួយគ្រួសារប៉ុន្មានម៉ែត្រៗ ហើយចាប់ដីហ្នឹងអ្នកខ្លះបានទៅចាប់ហើយអ្នកខ្លះទៀតអត់បានទៅចាប់ទៅ!

ដានីៈ ដីចំការដីស្រែហ្នឹង?

ប៉ាចៈ បាទ! អ្នកខ្លះក៏ទិញ ទិញគេទៅដល់ពេលយើងត្រូវគ្នាអញ្ចឹងចាប់បានយើងទិញគេទៅព្រោះនៅថោកអត់ថ្លៃដូចឥលូវទេ ឥលូវថ្លៃណាស់! លូកមិនបានទេយើងអ្នកអត់រកលុយទិញផ្ទះទិញដីនៅមិនបានទេ ហើយដីតាមថ្នល់នេះក៏មិនធំដែរដូចថា២០ម៉ែត្រ៣០ម៉ែត្រហ្នឹងក្បាលម៉ារ៉ៃពីររ៉ៃម្នាក់ មានអាដីទៅចំការនោះបានយើងចាប់បានធំៗបួនដប់រ៉ៃអីចឹងទៅក្នុងមួយគ្រួសារ ហើយអាខ្លះអត់ក៏ទិញគេទៅ ។

ដានីៈ ចុះខុសគ្នាម៉េចដែរពេលដែលយើងក្រោយពីសមាហរណកម្មម៉ោហើយកាលពីមុនសមាហរណកម្ម បើតាមពូគិតខុសគ្នាម៉េចទៅ?

ប៉ាចៈ អាហ្នឹងបើតាមអារម្មណ៍របស់យើងដូចថាខុសត្រង់ថាយើងវាបានជួបជុំប្តីប្រពន្ធកូនចៅយើងរស់នៅបានសមរម្យអត់មានលំបាកទេ ក្នុងអារម្មណ៍របស់យើងដូចថារីករាយដែលសម្តេចគាត់បានផ្សះផ្សារម៉ោបានត្រូវគ្នាយើងក៏រីករាយក្នុងការដូចថាលែងចង់ធ្វើសង្រ្គាមទៀត ណាំឲ្យត្រូវគ្នាអញ្ចឹងទៅប្រទេសជាតិយើងបានកសាងបានសប្បាយ វាបានស្រួលជាងកាលយើងនៅវៃគ្នាមួយថ្ងៃៗមិនបានជួបជុំប្រពន្ធកូន លឺកាំភ្លើងលឺគ្រាប់រាល់ថ្ងៃមួយថ្ងៃអត់ឈប់ទេ ហើយឥលូវយើងវាធូរស្រាលអារម្មណ៍ដូចថាដែលបានរស់នៅវាសមរម្យនិយាយ ទៅយើងអត់មានអត់ក្រអីតែវាស្រួល ឈឺស្កាត់អីក៏បានមានពេទ្យមានអីត្រឹមត្រូវទៅ ដូចថាវាស្រួលជាងកាលយើងនៅទាហានឆ្ងាយណាស់!

ដានីៈ ចុះជីវភាព ជីវភាពយើងយ៉ាងម៉េចដែរ ដែលកាលសង្រ្គាមយើងមានរបបមានអីមានអង្ករមានម្ហូប?

ប៉ាចៈ បាទ!

ដានីៈ ឥលូវយើងរកខ្លួនឯង?

ប៉ាចៈ បាទរកខ្លួនឯង!

ដានីៈ បើគិតទៅមួយណាស្រួលជាង?

ប៉ាចៈ អានេះបើនិយាយទៅវាដូចថាពីមុនយើងមានរបបពីខាងលើចែកឲ្យថាវាស្រួលដែរតែបច្ចុប្បន្ននេះយើងរកស៊ីខ្លួនឯងចិញ្ចឹមជីវិតខ្លួនឯងវាលំបាកក៏ថាបានថាស្រួលក៏ថាបាន ដូចថាជីវភាពយើងរកបានប៉ុន្មានយើងហូបប៉ុណ្ណឹងទៅហើយ យើងចង់ដើរ ហើរទៅណាបាន តែកាលជំនាន់នៅវ៉ៃគ្នាយើងវាពិបាកដែរយើងវាមានវិន័យមានច្បាប់ត្រឹមត្រូវ យើងទាហានអត់បានស្រួលទេ អញ្ចឹងបានថាសព្វថ្ងៃវាសមរម្យដូចថាយើងរកស៊ីចិញ្ចឹងខ្លួនឯងតែយើងឲ្យតែមានច្បាប់ដើមមានសំបុត្រដើមទៅដល់ណាក៏បានដែរអត់អីទេ!

ដានីៈ បាទ!

ប៉ាចៈ វាធូត្រង់ហ្នឹងបានដេកជុំប្រពន្ធកូនចៅអីចឹងទៅ ហើយដូចយើងពីដើមអត់សូវបានដេកជុំគ្នាប៉ុន្មានទេងាកមុខងាកក្រោយគេវ៉ៃគ្នាហ្នឹង!

ដានីៈ បាទ!

ប៉ាចៈ រត់លូនរហូត ឈ្នះគេក៏នៅចាញ់គេក៏រត់ទៅ ដូចឥលូវវាស្រួល យើងលំបាកតែខាងរកចិញ្ចឹងជីវិតមែនតែយើងវាស្រួលក្នុងការរស់នៅរបស់យើង!

ដានីៈ ចុះនៅភូមិសាស្ត្រយើងដែលនៅម៉ាឡៃហ្នឹងបើយើងនិយាយពីដំបូងហើយបន្ទាប់ម៉ោវាប្រែប្រួលយ៉ាងម៉េចដែរ? ដូចថាពេលដែលពូម៉ោហ្នឹងវាមានលក្ខណៈយ៉ាងម៉េចហើយបន្ទាប់ម៉ោសមាហរណកម្មហ្នឹងយ៉ាងម៉េចហើយមកដល់ឥលូវហ្នឹងវាប្រែប្រួលយ៉ាងម៉េច?

ប៉ាចៈ អានេះបើយើងនិយាយពីការប្រែប្រួលគឺវាប្រែប្រួលច្រើនមែនទែនដូចថាយើងតាំងពីព្រៃរហូតមកដល់វាល ហើយការរស់នៅតាំងពីការលំបាករហូតដល់ស្រួលហើយ យើងដេកមិនបានជុំគ្នាឥលូវយើងបានដេកជុំគ្នា ហើយក្នុងស្រុកភូមិយើងដូចថាស្គាល់គ្នាអញ្ចឹងហើយ ទៅណាក៏ដើរបានស្រួល ពីមុនយើងដើរក៏អត់បានព្រោះគ្រោះថ្នាក់ ម្យ៉ាងមីនម្យ៉ាងទាហានអីចឹងទៅ ហើយដូចសព្វថ្ងៃយើងចង់ដើរហើរទៅណាក៏អត់មានគ្រួសថ្នាក់ យើងមានច្បាប់មានទម្លាប់ អញ្ចឹងបានថាពីមុនហើយនឹងឥលូវវាខុសគ្នាឆ្ងាយណាស់!

ដានីៈ ខុសគ្នាឆ្ងាយ?

ប៉ាចៈ បាទ! ទោះបីយើងរកស៊ីមានការខ្វះខាតតិចតួចក៏យើងសប្បាយចិត្តអត់មានពិបាកចិត្តអី ច្រើន!

ដានីៈ ពូមានដឹងថានៅម៉ាឡៃហ្នឹងកាលពីមុនយើងចូលម៉ោហ្នឹងម៉ាឡៃនៅក្នុងស្រុកណា? កាលពីមុនឆ្នាំ៧៩?

ប៉ាចៈ ប្រហែលនៅក្នុងស្រុកបាត់ដំបង ព្រោះកាលហ្នឹងខេត្តបន្ទាយមានជ័យអត់ទាន់កើតទេកាលពីយើងអត់ទាន់មកនៅណា៎!

ដានីៈ ស្រុកបាត់ដំបង?

ប៉ាចៈ អត់ដឹងស្រុកណាដែរព្រោះខ្ញុំអត់សួរដឹងដែរ! បើតាមមើលទៅប្រហែលជាខេត្តបាត់ដំបង ព្រោះខេត្តបន្ទាយមានជ័យទើបតែកើតទេ ដល់ស្រុកមិនដឹងស្រុកអី តែបើក្នុងនេះអាចនៅខេត្តបាត់ដំបង!

ដានីៈ ចុះកាលជំនាន់បីឆ្នាំពូអាសារទៅលេងផ្ទះទេ? ហើយទៅលេងបានជួបម្ដាយជួបអីទេ?

ប៉ាចៈ អត់! អត់បានទៅទេ កាលពេលបីឆ្នាំហ្នឹងអត់បានទៅទេ!

ដានីៈ ចុះកាលទៅជួបម្ដាយនៅឆ្នាំ៧៦?

ប៉ាចៈ អាហ្នឹងអត់បាននៅក្នុងស្រុកណានៅស្រុកគេតើ ខ្ញុំទៅហ្នឹងគេឲ្យទៅដឹកអីឲ្យគេហ្នឹង តែក្នុងស្រុកភូមិខ្លួនឯងអត់ដែលបានទៅទេ មើលឃើញដែរតែអត់ដែលហ៊ានចូល មើលឃើញដំបូលផ្ទះដែរ ជំនាន់ហ្នឹងបើថាយើងនិយាយទៅដូចថាគេយកទៅវ៉ៃចោលបណ្ដើរៗ យើងក៏អត់ទុកចិត្តខ្លួនយើងដែរ អត់ដឹងថាយើងខុសឬត្រូវទេ អត់ហ៊ានទេខ្លាចចិត្តខ្លួនឯងមិនដឹងថាគេធ្វើបាបយើងដែរឬអត់!

ដានីៈ ចុះកាលហ្នឹងពូធ្លើកង៏ទ័ពដឹងថាមានគេយកទៅវ៉ៃចោលបណ្ដើរៗដែរអត់?

ប៉ាចៈ មាន!

ដានីៈ មានដែរ?

ប៉ាចៈ មានបណ្ដើរៗ ចុះខ្ញុំនៅទាហានហ្នឹងគេយកម៉ោមានមេៗ ហើយមានពួកគ្រូពួកអីចឹងណា៎ គេយកមកធ្វើបាប ហើយយើងគ្រាន់តែឃើញតែយើងមិនដឹងថាយ៉ាងម៉េចទេព្រោះយើងតូចតាចយើងចូលមិនដល់ដែរណា៎ គ្រាន់តែដឹងថាមានគេយកមកសម្លាប់ចោលបណ្ដើរៗ ហើយយកមកធ្វើបាបបណ្ដើរៗហើយ!

ដានីៈ ចុះកាលហ្នឹងពូធ្វើទាហាននៅអង្គភាពអីដែរ?

ប៉ាចៈ កាលហ្នឹងខ្ញុំនៅក្នុងកងតំបន់!

ដានីៈ នៅក្នុងកងតំបន់ ចុះក្រោយម៉ោពឆ្នាំ?

ប៉ាចៈ ដល់ពឆ្នាំហ្នឹងហើយបានខាងលើហ្នឹងរើសខ្ញុំយកមកពាយ័ព្យនេះ ឆ្នាំ១៩៧៦ណា៎!

ដានីៈ បាទ!

ប៉ាចៈ ខ្ញុំមកនៅពាយ័ព្យនេះរហូតម៉ោ!

ដានី៖ នៅជាមួយវៀតណាមមែន?

ប៉ាច៖ កាលហ្នឹងមកនៅនេះមកនៅកន្លែងតាញឹមហ្នឹងបានប៉ុន្មានខែ ដល់ហើយបានគេដកខ្ញុំទៅនៅខាងផ្លូវពួកវិញជាមួយតាភាពយើងហ្នឹង!

ដានី៖ ចុះតាភាពហ្នឹងគាត់នៅតាំងពីជំនាន់ពាឆ្នាំហ្នឹងដែរ?

ប៉ាច៖ អត់ទេគាត់ទើបតែម៉ោពីកើតដូចគ្នា!

ដានី៖ ប៉ុន្តែកាលពីជំនាន់ពាឆ្នាំពូម៉ោនៅជាមួយតាញឹម?

ប៉ាច៖ បាទនៅហ្នឹងបានប៉ុន្មានខែ!

ដានី៖ បានប្រហែលប៉ុន្មានខែ?

ប៉ាច៖ បានប្រហែលជាពាខែខ្ញុំមកនៅបាត់ដំបងហ្នឹង ការពារកន្លែងគាត់ការពាររោងម៉ាស៊ីនសារ៉ូពីរសារ៉ូបីហ្នឹង!

ដានី៖ បាទ!

ប៉ាច៖ ដល់ហើយបានគេរើសពួកខ្ញុំម៉ោតាមព្រំដែនទៅម៉ាដូវផ្លូវពួក!

ដានី៖ នៅជាមួយពីណាគេ?

ប៉ាច៖ នៅជាមួយតាវែង!

ដានី៖ តាវែង?

ប៉ាច៖ បាទ! តាវែងហ្នឹងនៅខាងផ្លូវពួកកាលហ្នឹង គាត់កងពលកាលហ្នឹង!

ដានី៖ កងពលតាវែង?

ប៉ាច៖ បាទ!

ដានី៖ នៅហ្នឹងរហូតដល់ពេល...?

ប៉ាច៖ នៅហ្នឹងរហូតដល់ពេលយួនចូលម៉ោហ្នឹង ដល់យួនចូលម៉ោវ៉ៃទៅដូនកាលនៅដូនកាលឆ្លងម៉ោខាងត្បូងផ្លូវដូចខ្ញុំនិយាយអញ្ចឹងអត់នៅហ្នឹងទេ!

ដានី៖ បាទ!

ប៉ាច៖ ដល់ពេលនេះគេឲ្យម៉ោនេះវិញម៉ោ មុនដំបូងខ្ញុំនៅខាងផ្លូវពួកនោះទេកាលពីយួនចូលម៉ោដល់ស្វាយដល់អីហ្នឹងក្លាមហ្នឹងខ្ញុំនៅខាងផ្លូវពួក!

ដានី៖ កាលជំនាន់ហ្នឹងពូមានដឹងថាពីណាគេចាប់គេសម្លាប់អីចឹង ពូមានដែលធ្លាប់បានជួយអីពីណាទេដែលត្រូវគេរកសម្លាប់រកអីចឹង?

ប៉ាច៖ អត់ទេ!

ដានី៖ អត់ទេ?

ប៉ាច៖ បាទ! អត់ទុកចិត្តខ្លួនឯងដែរ យើងថ្ងៃណានេះគេធ្វើបាបដែរ!

ដានី៖ ចុះពេលសម័យ៧៩ហ្នឹងពូមានធ្លាប់ឃើញពីណាតាមផ្លូវ នៅអតីតធ្លាប់ជួយជាអន្ទុរជាបាយអីទឹកអីទេ?

ប៉ាច៖ ធ្លាប់ជួយ ធម្មតាយើងដើរទៅកាលហ្នឹងយើងនៅព្រៃដល់ពេលឃើញមានអញ្ចឹងទោយើងមិនជួយ បើយើងមានកម្លាំងយើងមិនជួយតែបើយើងឈឺដែរមិនដឹងធ្វើម៉េចទេ ប៉ុន្តែភាគច្រើនមិនសូវបានអ្នកណាជួយអ្នកណាប៉ុន្មានទេព្រោះយើងឈឺរៀងៗខ្លួនដែរ ដល់អញ្ចឹងយើងអ្នកណាដើររួចក៏ដើរទៅហើយអ្នកណាឈឺក៏ឈឺទៅ!

ដានី៖ បាទ!

ប៉ាច៖ ដល់អញ្ចឹងអ្នកខ្លះក៏បែកអន្តភាពទៅ អ្នកខ្លះយើងក៏ជួយយកទៅដាំបាយដាំទឹកអីឲ្យ!

ដានី៖ ចុះប្រជាជនពេលហ្នឹងពូមានជួបប្រជាជនដែរទេ?

ប៉ាច៖ អត់ទេ កាលខ្ញុំម៉ោអត់មានជួបប្រជាជនទេ!

ដានី៖ អត់មានប្រជាជនរត់ម៉ោតាមទេ?

ប៉ាច៖ អត់ទេ! មានសុទ្ធតែទាហានទេ!

ដានី៖ ដល់ក្រោយម៉ោនៅឆ្នាំ៩៣ហ្នឹងពូបានទៅលេងផ្ទះ?

ប៉ាច៖ បាទ! កាលហ្នឹងត្រូវគ្នាពួកអ៊ុន តាក់ម៉ោ អាហ្នឹងបានខ្ញុំកាត់ចិត្តទៅលេងស្រុក ទៅបានម្តងហ្នឹងហើយម៉ោវិញគេវៃគ្នាមួយព្រឹបទៀតបានយើងត្រូវគ្នា ។

ដានី៖ ចុះពេលដែលពូទៅលេងផ្ទះដំបូងយ៉ាងម៉េចដែរយើងកាលហ្នឹងដូចថាបែកគ្នាយូ២០,៣០ឆ្នាំហើយ ហើយបានទៅលេងផ្ទះដូចថាអារម្មណ៍យ៉ាងម៉េចដែរពេលដែលយើងបានទៅលេងផ្ទះលើកទីមួយអញ្ចឹង?

ប៉ាច៖ អារម្មណ៍មុនដំបូងភ័យដែរតែអត់ទុកចិត្តដែរព្រោះយើងធ្លាប់ធ្វើទាហានហើយយើងទៅចោលខ្លាចគេធ្វើបាបដែរហ្នឹង តែដល់ពេលយើងទៅអត់អីដែរ!

ដានី៖ អត់អីទេ?

ប៉ាច៖ យើងទៅគេថាសុខស្រួលអញ្ចឹងទៅ ហើយអ្នកខ្លះក៏គេមិនដឹងថាយើងយ៉ាងម៉េចដែរ គេអត់ដឹងដែរគេអត់ដឹងថាយើងទៅពីណាពីណីគេអត់ចាប់អារម្មណ៍ដែរ ហើយយើងទៅមុនដំបូងអញ្ចឹងអត់សូវហ៊ានដើរទៅណារហេតរហូតទេ ព្រោះខ្លាចដែរ!

ដានី៖ ខ្លាចដែរ?

ប៉ាចៈ ព្រោះអត់ទុកចិត្តខ្លាចគេធ្វើបាបយើង បើទៅស្រុកភូមិគេប្ដែកដែរ!

ដានីៈ ទៅនោះរកផ្ទះឃើញដែរ?

ប៉ាចៈ រកឃើញខ្ញុំនៅចំណាំបាន!

ដានីៈ នៅចំណាំបាន?

ប៉ាចៈ បាទ!

ដានីៈ ដល់ពេលចូលទៅដំបូងជួបពីណាខ្លះទៅ?

ប៉ាចៈ មុនដំបូងជួបតែឪ ហើយនឹងបងប្អូន!

ដានីៈ គាត់បែកពូយូអញ្ចឹងទៅដល់គាត់ចំណាំពូបានទេ?

ប៉ាចៈ គាត់ចំណាំបាន! បើនិយាយទៅខ្ញុំគ្មានអ្នកណាថារស់ទេ មីងមាម៉ែអីសុទ្ធតែថាខ្ញុំស្លាប់ព្រោះអត់ដឹងថាយើងទៅណាទេតាំងពី៧៩ម៉ោ មួយៗអត់មានដឹងដំណឹងថាយើងទៅណាទេ មានអ្នកខ្លះរហូតដល់ឥលូវអត់ដែលទៅស្រុកទេ អត់ដឹងដំណឹងចេះតែសួរទៅថាធ្លាប់ឃើញធ្លាប់អីអញ្ចឹងពេលខ្ញុំទៅអញ្ចឹង គេសួរថាមានឃើញអានេះមានឃើញអានោះទេ ខ្ញុំថាអត់ដឹងដែរព្រោះវាច្រើនដែរអន្តភាព មិនដឹងថាអ្នកណាទៅខាងណាអ្នកណាទៅខាងណី អ្នកណាបានទៅក៏ទៅៗ ហើយអ្នកណាអត់បានទៅក៏អត់ហ៊ានទៅកាលជំនាន់ហ្នឹង ។

ដានីៈ ចុះអារម្មណ៍យ៉ាងម៉េចដែរពូពេលទៅជួបបងប្អូនជួបឪពុកលើកទីមួយ?

ប៉ាចៈ មានអារម្មណ៍ថាសប្បាយរីករាយបងប្អូនឪពុកម្ដាយនៅអញ្ចឹងទៅ ហើយឪពុកម្ដាយក៏គាត់អរព្រោះកូននៅអញ្ចឹងព្រោះមិននឹកស្មានថាកូននៅរស់ណា៎ ចុះបើបែកឡើង២០,៣០ឆ្នាំ ហើយមិនដែលបានទៅដល់អញ្ចឹងឪពុកម្ដាយបងប្អូនចេះតែបន់ឲ្យកូនចៅនៅរស់ អ្នកខ្លះក៏បានអ្នកខ្លះក៏ស្លាប់អញ្ចឹងទៅ!

ដានីៈ ចុះដូចញាតិមិត្តជិតខាងហើយមិត្តភ័ក្រ្តពូកាលពីក្មេងៗមានដែលបានជួបទេពេលហ្នឹង?

ប៉ាចៈ បានជួបខ្លះព្រោះអ្នកខ្លះគេទៅធ្វើទ័ពដែរ បែកគ្នាអ្នកខ្លះក៏ស្លាប់ទៅ គិតទៅវាស្លាប់ច្រើនដែរអ្នកចូលមកធ្វើទ័ពធ្វើទាហានហ្នឹង ខ្លះធ្វើទាហានខាងរដ្ឋកម្ពុជាទៅ!

ដានីៈ ចុះដំបូងយើងទៅដូចថាអ្នកជិតខាងអីស្គាល់ដែរ?

ប៉ាចៈ ស្គាល់!

ដានីៈ ដំបូង?

ប៉ាចៈ ស្គាល់តែចាស់ៗ បើក្មេងអត់សូវស្គាល់ទេព្រោះបែកគ្នា២០,៣០ឆ្នាំហើយ គេមានកូនមានទាំងចៅទៀតនោះ ដល់អញ្ចឹងវាអត់សូវស្គាល់ទេ តែក្មួយៗរបស់ខ្ញុំក្រោយៗហ្នឹងក៏អត់សូវស្គាល់ដែរ បើម៉ាស្រករគ្នាហ្នឹងស្គាល់!

ដានីៈ ស្គាល់តែចាស់ៗ?

ប៉ាចៈ បាទ! ដល់ក្មេងវាអត់ស្គាល់ទេ ចុះបើ១០,២០វាឡើងមានប្ដីមានប្រពន្ធហើយហ្នឹងអាក្មេងក្រោយៗហ្នឹង ដូចប្អូនខ្ញុំអីទៅដល់វាមានប្រពន្ធមានប្ដីហើយមានទាំងចៅវាការទៀត មានកូនការ ហើយយើងនេះអត់ទាន់មានកូនការណា៎!

ដានីៈ បាទ!

ប៉ាចៈ ចុះវាការតាំងពីនៅក្មេងកាលវានៅស្រុកនោះ!

ដានីៈ បាទ!

ប៉ាចៈ ហើយយើងនេះមានអីនៅយូ!

ដានីៈ ឆ្នាំណាបានទៅលេងទៀត?

ប៉ាចៈ ខ្ញុំទៅទើបតែម៉ោដែរទើបទៅខែ៦នេះទៅការប្អូន!

ដានីៈ អ៎ទៅការប្អូន?

ប៉ាចៈ បាទ! ទៅញឹកដែរហ្នឹង មួយឆ្នាំពីរឆ្នាំអីទៅ បើមានធុរៈមួយឆ្នាំអីទៅពីសារអញ្ចឹងកាលឪពុកឈឺខ្ញុំទៅមួយសារ កាលគាត់អន់ម៉ោដល់ផ្ទះបានបួនដប់ថ្ងៃគេម៉ោប្រាប់ថាស្លាប់ហើយដល់ប្រាប់ថាស្លាប់ហើយទៅមួយសារទៀត ជួនកាលមួយឆ្នាំទៅពីរសារក៏មាន! ខ្លះក៏ពីរឆ្នាំអីទៅម្ដងអញ្ចឹងទៅ ជួនកាលពីឆ្នាំទៅតាមយើងអត់មានធុរៈអីណា៎ បើមានធុរៈវាគេចអត់ផុត បើប្អូនអីកូនចៅអីបន្តិចបន្តួចយើងចេះតែខានបានដូចការដូចអី ដល់ពេលគាត់ស្លាប់គេចអត់រួចត្រូវតែទៅ ឈឺស្កាត់អីត្រូវតែទៅ។

ដានីៈ ចុះពូបើនិយាយពីអារម្មណ៍នឹងមនោសញ្ចេតនាវិញកាលពូនៅស្រុកភូមិកាលនៅក្មេងៗ ហើយយើងបែកម៉ោរហូតម៉ោនៅម៉ាឡៃយើងនេះ នៅតាំងពី៨០ម៉ោរហូតដល់ឥលូវវា៣០ឆ្នាំហើយ យើងមានមនោសញ្ចេតនា យើងមានញាតិមិត្ត មានមិត្តភ័ក្ដ្រដូចថាភាពស្និទស្នាលក៏វាច្រើន បើយើងប្រៀបធៀបទៅកាលស្និទស្នាលអារម្មណ៍រវាងនៅម៉ាឡៃនឹងនៅស្រុកកំណើតហ្នឹងយ៉ាងម៉េចដែរ?

ប៉ាចៈ អានេះបើប្រៀបធៀបដូចថាពីដើមនៅក្នុងស្រុកភូមិនោះវាធម្មតាហើយវាម្យ៉ាង ដល់ពេលទៅម្ដងៗដូចនឹកនេះដែរដូចថាស្រុកភូមិនៅនេះទៅហើយ!

ដានី: ដូចថាមានអារម្មណ៍ថានៅនេះដូចជាស្រុកភូមិកំនើតវិញ?

ប៉ាច: បាទដូចជាស្រុកកំណើត! តែអារម្មណ៍វានៅតែនឹកឃើញដល់ស្រុកកំណើតធ្លាប់លំបាក វេទនាស្រណុកស្រួលម៉េចក៏នៅតែនឹកឃើញដែរ តែអារម្មណ៍សំខាន់វានឹកម៉ោនេះជាងព្រោះយើងមានដីធ្លីផ្ទះសំបែងនៅនេះ ឪពុកម្តាយវាសំខាន់ដែរយើងនឹកដែរតែយើងទៅបានតែបួនដប់ថ្ងៃអញ្ចឹងបានត្រលប់ម៉ោវិញ អារម្មណ៍យើងវាទាញម៉ោខាងនេះខ្លាំងព្រោះយើងមានកូនមានចៅគិត តែចិត្តនៅតែនឹកឃើញស្រុកភូមិធ្លាប់រួមរស់!

ដានី: តែអត់ចង់ទៅរស់នៅនោះវិញទេ?

ប៉ាច: បាទអត់ទេ ទៅនៅនោះនឹកឃើញថាយើងវាអត់មានដីធ្លី ដូចថាឪពុកម្តាយបងប្អូនយើងដូចថាអត់មានអញ្ចឹងទៅដល់ពេលយើងទៅអញ្ចឹងបងប្អូនយើងច្រើនយើងមានដីធ្លីពីណាទៅដល់ពេលអញ្ចឹងអារម្មណ៍អត់សូវចង់ទៅនៅទេ ព្រោះនៅនេះទៅយើងវាមានដីមានធ្លីហើយដូចថាយើងមានលុយកាក់អីតិចតួចឲ្យទៅគាត់ទៅក៏វាម្យ៉ាង ដល់ទៅស្រុកភូមិបងប្អូនច្រើនហើយអត់មានដីធ្លីមិនដឹងទៅនៅណា ទៅនៅជាន់គ្នាម៉េចកើតព្រោះខ្ញុំនៅស្រុកភូមិពីដើមខ្ញុំលំបាកដែរជីវភាពបងប្អូនខ្ញុំសព្វថ្ងៃក៏លំបាកដែរ តែខ្ញុំនេះក៏មិនធូរណាស់ណាគ្រាន់ថាបានម៉ាហូបគ្រប់គ្រាន់អញ្ចឹងទៅ យើងមានដីធ្លីគ្រាន់ធ្វើអញ្ចឹងទៅ ដល់ទៅស្រុកភូមិនោះវាពិបាកទៅម្តងឃើញតែពិបាកដូចថាមានធុរៈអីទៅបងប្អូន ខ្លះដូចថាចង់ទៅធ្វើបុណ្យឪពុកម្តាយ បងប្អូនឪពុកខ្ញុំស្លាប់ហ្នឹងខ្ញុំថាបងប្អូនមានប៉ុន្មានក៏ជួយទៅហើយខ្វះប៉ុន្មានចាំខ្ញុំធ្វើណា៎ ដល់អញ្ចឹងខ្ញុំទទួលបន្ទុកធំជាងគេ ដូចថាបងប្អូនគ្នាវាអត់ហើយយើងវាគ្រាន់ជាងគេបន្តិចវាត្រូវទទួលបន្ទុកខ្លាំងជាងគេ យើងអត់មានបង្ខំថាត្រូវតែចេញប៉ុណ្ណេះប៉ុណ្ណោះទេ យើងត្រូវយល់ដែរថាបងប្អូនគ្នាយើងក៏មិនមានដែរតែយើងមានប៉ុន្មានខំបេះបោចយកទៅធ្វើបុណ្យឲ្យគាត់ឲ្យហើយៗ មិនមែនថាយើងមានលុយចាយមិនអស់ទេគឺផុតមុខផុតក្រោយដូចតែគ្នា ទេ!

ដានី: បាទខ្ញុំយល់!

ប៉ាច: បាទ!

ដានី: សព្វថ្ងៃពូដូចថាធ្វើកង់ទ័ពអញ្ចឹងនៅក្នុងអត្តភាពកង់ទ័ពទៀតឬក៏ឈប់ហើយ?

ប៉ាច: ខ្ញុំផ្អាកហើយព្រោះខ្ញុំរបួសច្រើនវាខ្សោយ របួសតាំងពីជំនាន់លន់ នល់ពីរដងដល់ម៉ោសង្រ្គាមយួននេះបីដងទៀតអញ្ចឹងវា៥ដងហើយ ខ្ញុំធ្វើទុកអាក្លៅនេះធ្លាយពីរដងហើយកញ្ចឹងកនេះធ្វើទុកក្បាលសព្វថ្ងៃដែរ ហើយទើបតែបានសម្រាកពីរបីឆ្នាំនេះសុំច្បាប់

គេឲ្យចូលចំការណា៎ តែថវិការគេនៅបើកឲ្យយើងរាល់ខែដែរ គេនៅជួយយើង! រដ្ឋគេនៅជួយយើង សម្រាកបានពីរបីឆ្នាំដែរហើយបើគិតទៅ!

ដានី: កាលពីសមាហរណកម្មពូនៅធ្វើទាហានទេ?

ប៉ាច: នៅៗធ្វើទាហានរហូត!

ដានី: ទាហាននៅខាងណា?

ប៉ាច: នៅខាងកងពល៥១យើងសព្វថ្ងៃ!

ដានី: អញ្ចឹងចំការស្រែពូទៅធ្វើឬក៏ពូអត់ទៅធ្វើ?

ប៉ាច: កាលនេះខ្ញុំទៅធ្វើខ្លះកូនទៅខ្លះអញ្ចឹង ថ្ងៃណាជាយើងទៅបើថ្ងៃអត់ស្រួលខ្លួនក៏អត់ទៅឲ្យកូនទៅអញ្ចឹង ព្រោះចំការផលូវវាអត់យ៉ាប់ប៉ុន្មានទេយើងដូលគេទៅ ដូលអាត្រាក់ដូលអីទៅ យើងមានទៅកាប់ដៃណា៎ យើងគ្រាន់តែទៅមើលពេលបាញ់ថ្នាំបាញ់អី អញ្ចឹងយើងចេះតែទៅមើលទៅ ប៉ុន្តែដីខ្ញុំវាជិតៗដែរ!

ដានី: ចុះពូសព្វថ្ងៃហ្នឹងពូដែលព្រឹត្តិមានទាក់ទងនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអី ពូដែលតាមដានមើលទេ?

ប៉ាច: បើទូរទស្សន៍ប៉ះដែរ ប៉ុន្តែមិនសូវដែលបានតាមដានដែរហ្នឹង អាហ្នឹងបើតាមនិយាយទៅវាដូចថាអ្នកខ្លះគេគាំទ្រគាត់ហើយខ្លះទៀតមានដូចថាគំនុំណា៎ តែបើតាមខ្ញុំបើកទៅប៉ះដូចថាអន្តរជាតិអីដូចថាគាត់មិនធំគាត់ធ្វើតាមគេដែរគេបញ្ជាគាត់ដែរ បើគាត់មិនធ្វើគេមិនធ្វើបាបគាត់!

ដានី: ពីណាគេ?

ប៉ាច: តានេះហ្នឹង!

ដានី: តាណា?

ប៉ាច: តាឌុចហ្នឹងណា៎! គាត់គេមិនកាត់ទោសគាត់ព្រោះគាត់ខាងមេគុកមេអីហ្នឹង ដល់អញ្ចឹងយើងខ្លះថាគាត់អត់មានខុសទេព្រោះគាត់ធ្វើតាមគាត់ដែរ ដូចតែខ្ញុំសព្វថ្ងៃធ្វើទាហាននៅក្រោមគេបើគេបញ្ជាហើយយើងមិនធ្វើម៉េចនឹងកើត ទោះបីខុសទៅក៏ត្រូវតែធ្វើសិនដែរ!

ដានី: ចុះដូចជា៤នាក់ទៀតដែលតុលាការកំពុងតែឃុំខ្លួនបណ្តោះអាសន្ននៅតុលាការដូចជាអៀង សារី, ខៀវ សំផន, អៀង ធារិទ្ធអីម៉េចដែរ ពូយល់ឃើញយ៉ាងម៉េចដែរ?

ប៉ាច: អាហ្នឹងខ្ញុំយល់អត់ដល់ដែរ អាហ្នឹងខាងលើគាត់មិនដឹងសម្រេចយ៉ាងម៉េចព្រោះអានេះវាជាការខុសហើយធ្វើម៉េចមានតែសម្រេចទៅតាមខាងលើ!

ដានីៈ បើតាមចិត្តពូវិញពូយល់ឃើញថាតុលាការហ្នឹងគេឃុំខ្លួនពួកគាត់អញ្ចឹងត្រឹមត្រូវឬក៏មិនត្រឹមត្រូវ?

ប៉ាចៈ អាហ្នឹងបើតាមច្បាប់វាត្រឹមត្រូវហើយព្រោះយើងធ្វើកន្លងម៉ោប្រជាជនយើងវេទនា ច្រើន ប្រជាជនយើងដូចថាស្លាប់អស់ច្រើនអាហ្នឹងបើតាមខ្ញុំគិតទៅវាត្រឹមត្រូវដែរ ព្រោះអាហ្នឹងវាជាកំហុសរបស់គាត់ដែលជាអ្នកដឹកនាំ ទោះបីគាត់មិនបានធ្វើខ្លួនគាត់ក៏គាត់ជាអ្នកបញ្ជាឲ្យគេធ្វើដែរព្រោះមេៗមិនដែលធ្វើខ្លួនឯងទេមិនថាគេមិនថាយើងទេ ដល់ពេលខុសៗមេហ្នឹងហើយ ដូចប៉ុល ពត អញ្ចឹងគាត់ធំជាងគេដល់ពេលខុសៗគាត់ហ្នឹងហើយទោះបីគាត់មិនបានធ្វើក៏ខុសគាត់ ។

ដានីៈ ពូយល់ឃើញអញ្ចឹង?

ប៉ាចៈ បាទ! យល់ឃើញថាត្រឹមត្រូវដែរកាខុសឆ្គងរបស់គាត់ហើយនឹងការឃុំខ្លួនហ្នឹងវាត្រឹមត្រូវរបស់គេដែរព្រោះគេធ្វើតាមកំហុសរបស់គាត់ដែលគាត់បានប្រព្រឹត្ត ប្រទេសជាតិដែលត្រូវវេទនាកន្លងម៉ោហ្នឹង!

ដានីៈ បាទ! ខ្ញុំដូចជាអស់សំនួរសួពូហើយ ពូមានអីចង់បន្ថែមទៀតទេនូវអ្វីដែលខ្ញុំអត់ទាន់បានសួ ពូ?

ប៉ាចៈ ដូចអត់មានអីទេ!

ដានីៈ បាទអញ្ចឹងខ្ញុំសូមអរគុណពូច្រើនហើយដែលបានផ្ដល់ពេលវេលាសំណេះសំណាលរឿងជីវិតរបស់ពូដែលទាក់ទងនឹងសម័យខ្មែរក្រហម ហើយរឿងរ៉ាវរបស់លោកពូតាំងពីចេញពីផ្ទះរហូតមកដល់សព្វថ្ងៃនេះ អញ្ចឹងខ្ញុំសូមអរគុណពូច្រើន!

ប៉ាចៈ បាទ!

«ចប់»